# ឯកឧត្តមបណ្ឌិត ចម ប្រសិទ្ធ ជួបតំណាងក្រុមហ៊ុន ADDIDAS ប្រចាំទីក្រុងហុងកុង

នៅរសៀលថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ ឯកឧត្តមបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ពាណិជ្ជកម្ម បានអនុញ្ញាតឱ្យលោកស្រី **Maureen Vicker** និងលោក **Chan Choo Sing** តំណាងក្រុមហ៊ុន ADDIDAS ប្រចាំទីក្រុងហុងកុង និងសហការី ដើម្បីពិភាក្សាការងារនៅទីស្តីការក្រសួង ។

គោលបំណងនៃជំនួបពិភាក្សា ភាគីក្រុមហ៊ុន ADDIDAS ចង់សិក្សាស្វែងយល់ ពីវិស័យរោងចក្រកាត់ដេរ និងឱកាសវិនិយោគនៅកម្ពុជា។

លោកស្រី **Maureen Vicker** បានជំរាបជូនពីភាពល្បីល្បាញ នៃផលិតផលម៉ាក ADDIDAS ដែលទទួលការពេញនិយមលើទីផ្សារសកលលោក។ លោកស្រីបានមើលឃើញពីភាពរីកចំរើននៃវិស័យរោងចក្រកាត់ដេរនៅកម្ពុជា ហើយនេះក៏ជាបេសកកម្មលើកទីមួយរបស់លោកស្រី ដើម្បីទទួលបាននូវអនុសាសន៍ពី ឯកឧត្តមទេសរដ្ឋមន្ត្រី ទាក់ទងនិងសក្តានុពល និងលទ្ធភាពវិនិយោគនៅកម្ពុជា ។

ឯកឧត្តមបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានសំដែងនូវការស្វាគមន៍ ចំពោះប្រតិភូនៃក្រុមហ៊ុន ADDIDAS ដែលជាក្រុមហ៊ុនដ៏ល្បីលំដាប់ពិភពលោក មកកម្ពុជា។ ឯកឧត្តមបាន ជំរាបជូនថា: ការរីកចំរើននៃវិស័យរោងចក្រកាត់ដេរនៅកម្ពុជា ជាបន្តបន្ទាប់មកដោយសារកម្ពុជាទទួលបាន កេរ្តិ៍ឈ្មោះក្នុងការអនុវត្តរូបមន្ត **“ការធ្វើពាណិជ្ជកម្ម ផ្សារភ្ជាប់និងលក្ខខណ្ឌការងារ“** ដែលជាទំនុកចិត្តសំរាប់ អ្នកបញ្ជាទិញពីក្រៅប្រទេស។ ឯកឧត្តមទេសរដ្ឋមន្ត្រី បានគូសបញ្ជាក់ថា: ដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោក វិស័យរោងចក្រកាត់ដេរនៅកម្ពុជា ត្រូវប្រឈមនិងបញ្ហាមួយចំនួន តែឯកឧត្តមជឿថា: នេះគ្រាន់តែជាដំណាក់ កាលបណ្តោះអាសន្នប៉ុណ្ណោះ ពីព្រោះថា: ទន្ទឹមនិងមានរោងចក្រមួយចំនួនបិទទ្វារ ក៏មានរោងចក្រថ្មីៗ ថែមទៀត មកបណ្តាក់ទុននៅកម្ពុជាផងដែរ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាល ក៏បានខិតខំរិះរកវិធានការជាបន្តបន្ទាប់ ទាំងវិធានការខាងសារពើពន្ធ និងការសំរួលនីតិវិធីផ្សេងៗទៀត ដើម្បីជួយគាំទ្រដល់វិស័យកាត់ដេរ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី បានសំដែងនូវការស្វាគមន៍ជានិច្ច ចំពោះវត្តមានរោងចក្រ ម៉ាក ADDIDAS នៅកម្ពុជា ដោយឯកឧត្តម ទាញការចាប់អារម្មណ៍ថា: ផលិតផល ម៉ាក ADDIDAS ផលិតនៅហុងកុង គឺ សំរាប់ធ្វើការនាំចេញ ទៅទីផ្សារក្រៅប្រទេស ក៏ប៉ុន្តែប្រជាជន ហុងកុង និងប្រជាជនចិនទាំងមូល ក៏ត្រូវការ ផលិតផលម៉ាក ADDIDAS ដែលផលិតនៅកម្ពុជា ពីព្រោះចិនក៏ជាប្រទេសដែលបានផ្តល់ភាពអនុគ្រោះ ពាណិជ្ជកម្មដល់កម្ពុជាផងដែរ ។